D138/1/3

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១៨) |
| កាលបរិច្ឆេទឯកសារ | : | ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៩ |
| ភាគីដាក់សារណា | : | សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| ភាសាដើម | : | ភាសាអង់គ្លេស |
| ប្រភេទឯកសារ | : | សាធារណៈ |

**សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ក.ស.ច.សអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ**

**ដាក់ជូនដោយ:**

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គឹមសួន
លោក គង់ ពិសី
លោក យុង ផានិត
លោក ឡោ ជុនធី
លោក នី ចាន់ឌី
លោកស្រី Silke STUDZINSKY
លោក David BLACKMAN

**ជូនចំពោះ:**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម **ប្រាក់ គឹមសាន** ជាប្រធាន
ចៅក្រម **ន័យ ថុល**
ចៅក្រម **ហួត វុទ្ធី**
ចៅក្រម Katinka LAHUIS
ចៅក្រម Rowan DOWNING

**ចម្លងជូន:**

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក ពេជ្រ សម្បត្តិ

**ជនជាប់ចោទ**

លោក អៀង សារី

**សហមេធាវីការពារក្តីជនជាប់ចោទ**

លោក អាង ឧត្តម
លោក Michael KARNAVAS

ឯកសារដែលបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 26 / 03 / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Tuy

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 27 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Tuy

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

កញ្ញា ម៉ុច សុវណ្ណារី

លោក គីម ម៉េងឃី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោក Pirre-Olivier SUR

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោក Oliver BAHOUGNE

## I. ប្រវត្តិនីតិវិធី និងអង្គហេតុ

១. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩ ការិយាល័យសហចៅក្រមស៊ើបអង្កេត "ក.ស.ច.ស"បានចេញដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ[1] *"ដីកាសម្រេច"* ដែលដីកានេះសម្រេចឱ្យសហមេធាវីការពារក្ដីត្រូវធ្វើជាបន្ទាន់នូវកិច្ចដូចខាងក្រោម៖

(i) បញ្ឈប់ការផ្សព្វផ្សាយព័ត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធដល់កិច្ចស៊ើបសួរ នៅលើគេហទំព័ររបស់ខ្លួន លើកលែងតែបណ្ដាឯកសារទាំងឡាយណា ដែលមាននៅលើគេហទំព័ររបស់ អ.វ.ត.ក។

(ii) ដករាល់ឯកសារ ដែលហាមឃាត់ទាំងនោះចេញពីគេហទំព័ររបស់ខ្លួន ក្នុងរយៈពេល ៤៨ម៉ោង។

២. នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ សហមេធាវីការពារក្ដីរបស់ អៀង សារី បានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ក.ស.ច.ស អំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ *"បណ្ដឹងឧទ្ធរណ៍"* ដែលក្នុងបណ្ដឹងនោះ សហមេធាវីការពារក្ដីទាមទារឱ្យមោឃភាពដីកាសម្រេចរបស់ក.ស.ច.សចោល[2]។

## II. សង្ខេបនៃឧទ្ធរណ៍

៣. ឯកសារនានា ដែលមិនប៉ះពាល់ដល់សិទ្ធិនិងផលប្រយោជន៍របស់ភាគី មិនស្ថិតនៅក្នុងគោលការណ៍នៃភាពសម្ងាត់នោះទេ។

---

[1] *រឿងក្ដីលោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D138 ដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩។

[2] *រឿងក្ដីលោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D138/11/1 បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ក.ស.ច.ស អំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩។

៤. នៅពេលដែលឯកសារមួយត្រូវបានប្រកាសថាជាប្រភេទឯកសារ"សាធារណៈ" ឯកសារនោះនៅតែជាប្រភេទឯកសារ "សាធារណៈ" ហើយភាគីផ្សេងៗអាចយកឯកសារនោះទៅផ្សព្វផ្សាយបាន ដោយមិនគិតថាឯកសារនោះត្រូវបានផ្សព្វផ្សាយរួចហើយ ឬមិនទាន់បានផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់តុលាការនោះទេ។

## III. ឧទ្ទិករណ៍

៥. ការពិភាក្សាអំពីតម្លាភាពនៃតុលាការ គឺមានលក្ខណៈចាំបាច់និងសំខាន់ណាស់ និងដីការបស់ ក.ស.ច.ស បានប៉ះពាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីរបស់ពួកគាត់ផងដែរ។

៦. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានជួបប្រទះការលំបាកដូចសហមេធាវីការពារក្តីដែរ នៅពេលដែលមានការទាក់ទងនឹង៖

(i) គម្លាតពេលវេលាដ៏វែង រវាងការដាក់ឯកសារ និងការជូនដំណឹង និង

(ii) ការដែលមិនអាចដឹងបានថាតើ ឯកសារមួយណានឹងត្រូវបានជ្រើសរើសយកទៅផ្សព្វផ្សាយនៅលើគេហទំព័ររបស់តុលាការ។

៧. សូមលើកឧទាហរណ៍មួយប៉ុណ្ណោះមកបញ្ជាក់។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ "សេចក្តីអង្កេតទូទៅ" ស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី[3]។ ទោះបីជាយើងបានស្នើសុំជាច្រើនដងឲ្យធ្វើការផ្សព្វផ្សាយឯកសារនេះក៏ដោយ ក៏រហូតមកទល់សព្វថ្ងៃនេះ ឯកសារនេះមិនទាន់បានផ្សព្វផ្សាយជាសាធារណៈនៅឡើយ។ ប៉ុន្តែ យើងមានការភ្ញាក់ផ្អើល នៅពេលសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពី "សេចក្តីអង្កេតទូទៅ"[4] ត្រូវបានផ្សព្វផ្សាយភ្លាមៗនៅលើគេហទំព័ររបស់តុលាការ។ គោលការណ៍ នេះគឺជាគោលការណ៍ដែលពិបាកយល់ ឬមិនមានយុត្តិកម្មទាល់តែសោះ។

---

[3] *រឿងក្តីប្រឆាំង អៀង សារី* សេចក្តីអង្កេតទូទៅរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៣) ឯកសារលេខ C22/I/38។

[4] *រឿងក្តីប្រឆាំង អៀង សារី* សេចក្តីសម្រេចលើការទទួលយកសេចក្តីអង្កេតដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៣) ឯកសារលេខ C22/I/41។

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា ឯកសារដែលពាក់ព័ន្ធ មានបញ្ហាវើសអើងប្រឆាំងនឹងដើមបណ្តឹងរដ្ឋប្បវេណីក្នុងតុលាការ។

៨. វិធាន៥៦ នៃវិធានផ្ទៃក្នុង "*វិធានផ្ទៃក្នុង*" បានចែងថា កិច្ចស៊ើបសួរមិនត្រូវធ្វើជាសាធារណៈនោះទេ ប៉ុន្តែ ការបកស្រាយគោលបំណងនៃការកំណត់អំពីភាពជាសាធារណៈ ក៏មានចែងក្នុងវិធានដូចគ្នានេះផងដែរ ដែលថា "ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី [...]"។ ហេតុដូចនេះ វិធាននេះ ព្រមទាំងករណីលើកលែងនៅក្នុងវិធាននេះ គួរត្រូវបកស្រាយឱ្យត្រូវតាមគោលបំណងរបស់វា។

៩. នៅក្នុងយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិលផ្សេងៗទៀត ភាពសម្ងាត់នៃកិច្ចស៊ើបសួរ ត្រូវប្រើប្រាស់សម្រាប់គោលបំណងជាក់លាក់ និងត្រូវបានបកស្រាយឱ្យស្របតាមគោលបំណងនោះ។ នៅប្រទេសអាឡឺម៉ង់ គោលការណ៍នៃភាពសម្ងាត់គឺដើម្បីធានាថា កិច្ចស៊ើបសួរគឺជាដំណើរការដែលមិនអាចសម្រួលបានទេ និងដើម្បីធានាថា លក្ខខណ្ឌការពារខ្លួន សង្គម និងវិជ្ជាជីវៈចំពោះជនជាប់ចោទ ត្រូវបានបំពេញ[5]។ នៅប្រទេសបារាំង "ភាពសម្ងាត់ក្នុងដំណាក់ដំបូងនៃនីតិវិធីព្រហ្មទណ្ឌ មានន័យថា កិច្ចស៊ើបសួរអាចអនុវត្តដោយមិនចាំបាច់មានការទំនាក់ទំនងជាមុនរវាងអ្នកសមគំនិត ភស្តុតាងពាក់ព័ន្ធដែលត្រូវបានបំផ្លាញ និងសម្ពាធដែលត្រូវបានដាក់លើសាក្សីនោះទេ។ ទង្វើនេះបានបង្ហាញអំពីការពារសច្ចាធារណ៍នៃនិរទោស ក្នុងការទប់ស្កាត់សារព័ត៌មានមិនឱ្យផ្សព្វផ្សាយពីទោសកំហុស មុនពេលតុលាការចេញសេចក្តីសម្រេច [...]។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ គេបានទទួលស្គាល់ថា ការអនុវត្តភាពសម្ងាត់ច្រើនខ្លាំងពេក

[5] Bundesverfassungsgericht (Vorprüfungsausschuß), Beschluss 08.11.1983- 2 BvR 1138/ 83, in NStZ 1984, S. 228; Oberlandesgericht Braunschweig, Urteil vom 24.10.1974- 1 U 55/73, in NJW 1975, S. 651 (652); *សូមមើលសារព័ត៌មាន* Christian-Alexander Neuling, „ Strafjustiz und Medien – mediale Öffentlichkeit oder „justizielle Schweigepflicht" im Ermittlungsverfahren?", Onlinezeitschrift fuer höchstrichterliche Rechtsprechung im Strafrecht, HRRS 2006, ទំព័រទី ៩៧។

អាចបង្កឱ្យមានការរំលោភបំពានអំណាច ដោយសារតែទង្វើនេះបានធ្វើឱ្យជនសង្ស័យស្ថិតនៅក្នុងស្ថានភាពមួយដែលងាយនឹងរងគ្រោះ”[6]។

១០. ដោយសារតែគោលបំណងទាំងនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កត់សម្គាល់ថា ភាពសម្ងាត់នៃឯកសារ មិនមែនមានន័យត្រឹមតែរក្សាការសម្ងាត់ប៉ុណ្ណោះទេ។ គោលបំណងនៃភាពសម្ងាត់ គឺការពារសិទ្ធិនិងផលប្រយោជន៍របស់ភាគី។ ប៉ុន្តែ ប្រសិនបើឯកសារ/ព័ត៌មានណាមួយ មិនបានប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ភាគីនានានោះទេ ឯកសារ/ព័ត៌មានត្រូវតែដាក់ជាប្រភេទឯកសារសាធារណៈ។

១១. ផលប្រយោជន៍របស់ការកាត់សេចក្តី គឺធ្វើការស៊ើបអង្កេតដោយគ្មានឧបសគ្គ ដែលអាចនឹងមាន ដូចជាថា សាក្សី និងភស្តុតាងផ្សេងៗទៀតមិនត្រូវរងឥទ្ធិពលពីខាងណាទេ មិនត្រូវធ្វើឱ្យខ្សោយទេ ឬមិនត្រូវបំផ្លិចបំផ្លាញទេ និងការស៊ើបអង្កេតមិនត្រូវបានរាំងនោះទេ។

១២. ជនត្រូវចោទមានសិទ្ធិមិនបង្ហាញខ្លួនជាសាធារណៈ និងជនត្រូវចោទត្រូវតែបានទទួលនូវការធានាសិទ្ធិ នៃគោលការណ៍សច្ចាធារណ៍នៃនិរទោស។

១៣. ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិមិនបង្ហាញខ្លួនជាសាធារណៈ និងផ្តល់ចម្លើយរបស់ខ្លួននៅកន្លែងណាដែលមានសុវត្ថិភាព។

១៤. អនុលោមតាមវិធាន ៥៦(២) នៃវិធានផ្ទៃក្នុង មានតែសហចៅក្រមស៊ើបអង្កេតទេ ដែលជាអ្នកសម្រេច ថាតើមាន ឬក៏មិនមានករណីលើកលែងចំពោះភាពសម្ងាត់នៃកិច្ចស៊ើបសួរ ដើម្បីឱ្យសាធារណជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី។ ហេតុដូចនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំថា ក.ស.ច.ស គួរអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនតាមរបៀបឱ្យស្របនឹងគោលបំណងទាំងមូលរបស់វិធាន៥៦ នៃវិធានផ្ទៃក្នុង ជាជាងប្រកាសថា ឯកសារទាំងអស់ជាប្រភេទឯកសារសម្ងាត់។

[6] Catherine Ellinott, ច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសបារាំង, ប្រទេសប៉ូឡូញ (២០០១) ទំព័រ១៤, ១៦។

00292948



១៥. ហេតុដូចនេះ ឯកសារ/ព័ត៌មាននានា ដែលមិនប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ភាគីណាមួយទេ ឯកសារ/ព័ត៌មាននោះត្រូវតែផ្សព្វផ្សាយដល់សាធារណជនឲ្យបានដឹងឲ្យបានឆាប់រហ័សតាមតែអាចធ្វើទៅបាន និងផ្សព្វផ្សាយនៅលើគេហទំព័ររបស់តុលាការ ដើម្បីបង្កើននូវតម្លាភាពនៃដំណើរការនីតិវិធី និងដើម្បីធ្វើឲ្យសាធារណជនបានដឹងអំពីកិច្ចការរបស់តុលាការ។

១៦. ជាពិសេស នៅពេលដែលមានការលើកឡើងអំពីបញ្ហាច្បាប់ និងទឡ្ហីករណ៍នានា វាគ្មានហេតុផលណាមួយដែលមិនផ្សព្វផ្សាយបញ្ហាច្បាប់ និងទឡ្ហីករណ៍នោះទេ លើកលែងតែក្នុងករណីដែលត្រូវលាក់បាំងកិច្ចការរបស់អ.វ.ត.ក។ ភាពសម្ងាត់នៃកិច្ចស៊ើបសួរ មិនគួរធ្វើឲ្យទឡ្ហីករណ៍ផ្លូវច្បាប់ចំពោះមុខតុលាការ និងដំណើរការនីតិវិធីរបស់តុលាការ ក្លាយជាការសម្ងាត់នោះទេ។

១៧. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កត់សម្គាល់ថា ផ្នែកខ្លះនៃឯកសារសម្ងាត់ បានផ្សព្វផ្សាយនៅលើគេហទំព័ររបស់តុលាការ ជាសំណៅដែលកោសលុបរួចហើយ ដែលនេះបង្ហាញឲ្យឃើញថា យើងនៅតែអាចផ្សព្វផ្សាយឯកសារនានា ដែលមានមួយផ្នែកជាឯកសារសម្ងាត់[7]។

១៨. ជាការពិត គោលការណ៍ដូចគ្នាគួរត្រូវយកមកអនុវត្ត ប្រសិនបើឯកសារមិនប៉ះពាល់ដល់សិទ្ធិ ឬជីវភាពជាឯកជនរបស់ភាគីទេ និងប្រសិនបើភាគីពាក់ព័ន្ធបានបោះបង់សិទ្ធិរបស់ខ្លួនដោយផ្អែកតាមសេចក្តីសម្រេចដែលបានជូនដំណឹងនោះ ដូច្នេះមូលដ្ឋាននៃភាពសម្ងាត់លែងមានទៀតហើយ និងឯកសារអាចនឹងត្រូវប្រកាស "ជាសាធារណៈ"។

---

[7] *សូមមើលរឿងក្តី អៀង សារី* , ការឆ្លើយតបរួមគ្នារបស់សហមេធាវីតំណាងរដ្ឋប្បវេណី ទៅនឹងបណ្តឹងឧទ្ធរណ៍របស់អៀងសារី ប្រឆាំងនឹងដីកាសម្រេចស្តីពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន [កោសលុប] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D22/5/6 ចុះផ្សាយនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៩។

១៩. អនុលោមតាមមាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ[8] នៅពេលអនុវត្ត ឆន្ទានុសិទ្ធិទាក់ទងនឹងចំណាត់ថ្នាក់នៃឯកសារ ក.ស.ច.ស និងអ.ប.ជ គួរអនុវត្តដោយ អនុលោមតាមគោលបំណងនៃភាពសម្ងាត់ដែលលើកឡើងខាងលើនេះ និងគួរពិចារណាផង ដែរលើចំណាត់ថ្នាក់ឯកសាររបស់ភាគីដែលដាក់ឯកសារ។ ប្រសិនបើភាគីដាក់ឯកសារ គឺជា ភាគីតែមួយប៉ុណ្ណោះដែលអាចប៉ះពាល់នូវសិទ្ធិ និងផលប្រយោជន៍ដោយឯកសារនោះ សំណើរ របស់ពួកគាត់អំពីចំណាត់ថ្នាក់នៃឯកសារនោះ គួរតែត្រូវប្រត្តិបត្តិតាម។ ប៉ុន្តែ រហូតមកទល់ ពេលនេះ លក្ខខណ្ឌវិនិច្ឆ័យស្តីពីចំណាត់ថ្នាក់ឯកសារ នៅតែមានលក្ខណៈមិនច្បាស់ និងមិន មានតម្លាភាពទេ។

២០. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងបន្ថែមទៀតថា ឯកសារដែលត្រូវ បានតុលាការចាត់ថ្នាក់ជាប្រភេទ "សាធារណៈ" ត្រូវតែនៅជាប្រភេទសាធារណៈ និងមិនអាច ក្លាយជាឯកសារសម្ងាត់វិញ ដោយសារតែមូលហេតុដែលថា ផ្នែកកិច្ចការសាធារណៈមិនចង់ ផ្សព្វផ្សាយឯកសារនោះនៅលើគេហទំព័ររបស់តុលាការ។ ផ្នែកកិច្ចការសាធារណៈ មិនមាន អំណាចដោយខ្លួនឯងក្នុងការសម្រេច ថាតើឯកសារណាមួយត្រូវធ្វើការផ្សព្វផ្សាយ ឬឯកសារ ណាមួយមិនត្រូវធ្វើការផ្សព្វផ្សាយនោះទេ។

២១. លើសពីនេះ សហមេធាវីការពារក្តីបានស្នើសុំថា ឯកសារទាំងអស់ដែលបានប្រកាសជាប្រភេទ ឯកសារ"សាធារណៈ" (ឬនៅពេលឯកសារសម្ងាត់ត្រូវបានដាក់ជាសាធារណៈ ជាសំណៅ ដែលកោសលុប) ឯកសារនោះគួរត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រអ.វ.ត.ក។ ប៉ុន្តែផ្នែក កិច្ចការសាធារណៈ ហាក់ដូចជាធ្វើការជ្រើសរើស ថាតើឯកសារណាត្រូវផ្សព្វផ្សាយ ឬ ឯកសារមួយណាមិនត្រូវផ្សព្វផ្សាយ។ ប្រសិនបើផ្នែកកិច្ចការសាធារណៈ មិនបានផ្សព្វផ្សាយ ឯកសារទាំងអស់ដែលដាក់ក្នុងប្រភេទឯកសារ "សាធារណៈ" នៅលើគេហទំព័ររបស់ តុលាការទេ ដូច្នេះភាគីនានា មានសិទ្ធិផ្សព្វផ្សាយឯកសារទាំងអស់នោះ។

---

[8] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/កំណែលើកទី៣ ស្តីពីការដាក់ឯកសារចំពោះមុខអ.វ.ត.ក។

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមដាក់ជូនដោយសេចក្តីគោរព។

| | |
|---|---|
| **ហុង គីមសួន** | **គង់ ពិសី** |
| សហមេធាវី | សហមេធាវី |
| **យុង ផានិត** | **ឡោ ជុនធី** |
| សហមេធាវី | សហមេធាវី |
| **ទី ចាន់ឌី** | **Silke Studzinsky** |
| សហមេធាវី | សហមេធាវី |

ចុះហត្ថលេខានៅភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២00៩